# គោលនយោបាយ ស្តីពីសិទ្ធិទទួលបាន ព័ត៌មាន

ខែកញ្ញា ឆ្នាំ ២០១៨

ធនាគារអភិវឌ្ឍន៍អាស៊ី

# គោលនយោបាយ ស្តីពីសិទ្ធិទទួលបាន ព័ត៌មាន

ខែកញ្ញា ឆ្នាំ ២០១៨

ធនាគារអភិវឌ្ឍន៍អាស៊ី

© ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ ២០១៨
អគារលេខ ៦ វិថី ADB Avenu ក្រុង Mandaluyong ទីក្រុងម៉ានីល ១៥៥០ ប្រទេសហ្វីលីពីន
លេខទូរសព្ទ + ៦៣ ២ ៦៣២ ៤៤៤៤, ទូរសារ + ៦៣ ២ ៦៣៦ ២៤៤៤
www.adb.org

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ បោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៨។

លេខសម្គាល់ឯកសារបោះពុម្ពផ្សាយ TCS189627

តាមរយៈការកំណត់ឬលើកឡើងពីដែនដី ឬតំបន់ភូមិសាស្ត្រណាមួយ ឬតាមរយៈការប្រើពាក្យថា “ប្រទេស” ក្នុងឯកសារនេះ ADB ពុំមានគោលបំណងធ្វើការវិនិច្ឆ័យអំពីស្ថានភាពច្បាប់ ឬស្ថានភាពដទៃទៀតរបស់ដែនដី ឬតំបន់ណានោះឡើយ។

ADB លើកទឹកចិត្តឱ្យមានការបោះពុម្ព ឬចម្លងព័ត៌មាន សម្រាប់ការប្រើប្រាស់ក្នុងគោលបំណងផ្ទាល់ខ្លួន គោលបំណងអប់រំ និងគោលបំណងមិនមែនពាណិជ្ជកម្មតែប៉ុណ្ណោះ ដោយទទួលស្គាល់ថា ឯកសារនេះជា កម្មសិទ្ធិរបស់ ADB។ អ្នកប្រើប្រាស់ត្រូវបានហាមឃាត់មិនឱ្យលក់បន្ត ចែកចាយបន្ត ឬកែច្នៃឯកសារនេះ សម្រាប់គោលបំណងពាណិជ្ជកម្ម ដោយពុំមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាក់ច្បាស់ពី ADB នោះឡើយ។ សូមទាក់ទងមកកាន់អ៊ីមែល pubsmarketing@adb.org ប្រសិនបើអ្នកមានសំណួរ ឬយោបល់ពាក់ព័ន្ធនឹងខ្លឹមសារនៃឯកសារនេះ ឬប្រសិនបើអ្នកមានគោលបំណងចង់ទទួលបានការអនុញ្ញាត ពាក់ព័ន្ធនឹងសិទ្ធិថតចម្លង។

**សម្គាល់៖**

ការកែតម្រូវកំហុស ក្នុងឯកសារបោះពុម្ពផ្សាយរបស់ ADB អាចរកបាន តាមរយៈគេហទំព័រ http://www.adb.org/publications/corrigenda

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង**

អង្គភាពសិទ្ធិទទួលបានព័ត៌មាន
ការិយាល័យលេខាធិការ
disclosure@adb.org
www.adb.org/site/disclosure/main

នេះគឺជាសំណៅសម្រាប់បោះពុម្ពផ្សាយនៃឯកសារគោលនយោបាយផ្លូវការ ដែលទទួលបានការអនុម័តពីក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី កាលពីថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៨។

♻ Printed on recycled paper

| | |
|---|---|
| **អនុប្រធាន** | Bambang Susantono ផ្នែកគ្រប់គ្រងចំណេះដឹង និងការអភិវឌ្ឍប្រកបដោយចីរភាព |
| **គណៈកម្មាធិការដឹកនាំ** | Nessim Ahmad អគ្គនាយករង នាយកដ្ឋានអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការប្រែប្រួលអាកាសធាតុ (SDCC)<br>Shirin Hamid នាយកជាន់ខ្ពស់ការិយាល័យប្រព័ន្ធព័ត៌មាន និងបច្ចេកវិទ្យា (OIST)<br>Hun Kim អគ្គនាយក នាយកដ្ឋានអាស៊ីខាងត្បូង (SARD)<br>Tomoyuki Kimura អគ្គនាយក នាយកដ្ឋានយុទ្ធសាស្ត្រគោលនយោបាយ និងវាយតម្លៃ (SPD)<br>Christopher Stephens អគ្គមេធាវី ការិយាល័យអគ្គមេធាវី (OGC)<br>Vicky C.L. Tan នាយក នាយកដ្ឋានទំនាក់ទំនង (DOC)<br>Christopher Thieme អគ្គនាយករង នាយកដ្ឋានប្រតិបត្តិការវិស័យឯកជន (PSOD)<br>WooChong Um អគ្គនាយក SDCC<br>Eugenue Zhukov លេខាធិការ ការិយាល័យលេខាធិការ (OSEC) |
| **នាយកជាន់ខ្ពស់** | Vicky C.L. Tan, DOC |
| **ប្រធាន** | Omana Nair ផ្នែកព័ត៌មាន និងទំនាក់ទំនងសាធារណៈ, DOC |
| **ប្រធានក្រុម** | Karen Lane អ្នកឯកទេសជាន់ខ្ពស់ផ្នែកទំនាក់ទំនង, DOC |
| **សមាជិកក្រុម** | Marc Crowe និពន្ធនាយកជាន់ខ្ពស់, OSEC<br>Kurumi Fukaya អ្នកឯកទេសជាន់ខ្ពស់ផ្នែកសម្របសម្រួលប្រតិបត្តិការ, PSOD<br>Lesley Lahm ទីប្រឹក្សា និងជាប្រធានអង្គភាពទំនាក់ទំនងអន្តរស្ថាប័ន និងប្រតិបត្តិការមិនមែនរដ្ឋ, SPD<br>Lyailya Nazarbekova មេធាវីជាន់ខ្ពស់, OGC<br>Francesco Tornieri អ្នកឯកទេសជាន់ខ្ពស់ផ្នែកអភិវឌ្ឍន៍សង្គម, SARD<br>Patrick Vermeij អ្នកឯកទេសផ្នែកបច្ចេកវិទ្យាព័ត៌មាន, OIST<br>Nick Angelo Villaluz មន្ត្រីទំនាក់ទំនង, DOC |

ក្នុងការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រប្រចាំប្រទេស ការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងណាមួយ ឬការលើកឡើងពីដែនដី ឬទីតាំងភូមិសាស្ត្រណាមួយក្នុងឯកសារនេះ ធនាគារអភិវឌ្ឍន៍អាស៊ី ពុំមានបំណងធ្វើការវិនិច្ឆ័យពីភាពស្របច្បាប់ ឬស្ថានភាពផ្សេងទៀតរបស់ដែនដី ឬតំបន់ណានោះឡើយ។

# មាតិកា


ពាក្យកាត់ v

I. សារតា ១

II. ការណែនាំអំពីគោលនយោបាយនេះ ៦

III. គោលការណ៍ និងករណីលើកលែងនៃគោលនយោបាយនេះ ៧

ក. គោលការណ៍នៃគោលនយោបាយ ៧
ខ. ករណីលើកលែងចំពោះការបង្ហាញព័ត៌មាន ៨
គ. ការសម្រេចចិត្តផ្ទុយពីគោលនយោបាយនេះ ដើម្បីប្រយោជន៍សាធារណៈ (ការសម្រេចចិត្តផ្ទុយជាវិជ្ជមាន) ១៣
ឃ. បុព្វសិទ្ធិរបស់ ADB ក្នុងការកំហិតលើការទទួលបានព័ត៌មាន (ការសម្រេចចិត្តផ្ទុយជាអវិជ្ជមាន) ១៣
ង. ព័ត៌មានប្រវត្តិសាស្ត្រ ១៣

IV. សំណើសុំព័ត៌មាន និងបណ្ដឹងសាទុក្ខ ១៤

ក. សំណើសុំព័ត៌មាន ១៤
ខ. គណៈកម្មាធិការទទួលបន្ទុកសិទ្ធិទទួលបានព័ត៌មាន ១៤
គ. បណ្ដឹងសាទុក្ខ ១៥
ឃ. ទំនាក់ទំនងរវាងគោលនយោបាយស្ដីពីសិទ្ធិទទួលបានព័ត៌មានជាមួយនឹងគោលនយោបាយផ្សេងទៀត ១៧
ង. ការពិនិត្យឡើងវិញលើភាពអនុលោម ១៧

V. ការពិនិត្យតាមដាន និងការកែសម្រួលគោលនយោបាយនេះ ១៨

VI. កាលបរិច្ឆេទចូលជាធរមាននៃគោលនយោបាយនេះ ១៩

# ពាក្យកាត់

| | | |
|---|---|---|
| ADB | - | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AIC | - | គណៈកម្មាធិការទទួលបន្ទុកសិទ្ធិទទួលបានព័ត៌មាន |
| AIP | - | គោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាន |
| IAP | - | គណៈកម្មាធិការដោះស្រាយបណ្តឹងសាទុក្ខឯករាជ្យ |
| PCP | - | គោលនយោបាយទំនាក់ទំនងសាធារណៈ |

# I. សាវតា

១. គោលនយោបាយទំនាក់ទំនងសាធារណៈឆ្នាំ២០១១ (PCP) របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានទទួលការអនុម័តពីក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ និង ចូលជាធរមាននៅថ្ងៃទី ២ ខែមេសា ឆ្នាំ២០១២។ ការពិនិត្យកែសម្រួលឡើងវិញនេះត្រូវបានធ្វើឡើងដោយយោងទៅតាមគោលនយោបាយ។

២. **ដំណើរការពិនិត្យកែសម្រួលឡើងវិញ៖** ការពិនិត្យកែសម្រួលឡើងវិញទៅលើគោលនយោបាយទំនាក់ទំនងសាធារណៈនេះ បានចាប់ផ្តើមជាមួយនឹងការបង្កើតគណៈកម្មាធិការដឹកនាំមួយ ក្នុងខែ កក្កដា ឆ្នាំ២០១៦ ដើម្បីផ្តល់ការណែនាំជាយុទ្ធសាស្ត្រអំពីដំណើរការនេះ។ ក្នុងឆ្នាំ២០១៦ ធនាគារអភិវឌ្ឍន៍អាស៊ី បានធ្វើការពិនិត្យឡើងវិញទៅលើឯកសារគោលនយោបាយទំនាក់ទំនងសាធារណៈ និងការប៉ាន់ប្រមាណទៅលើធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត ព្រមជាមួយនឹងការពិគ្រោះយោបល់ផ្ទៃក្នុង។ គេហទំព័រសម្រាប់ការពិនិត្យកែសម្រួលឡើងវិញទៅលើគោលនយោបាយទំនាក់ទំនងសាធារណៈ ត្រូវបានបង្កើតឡើងនៅពេលដែលសេចក្តីព្រាងពិគ្រោះយោបល់លើកទី១នៃសំណើគោលនយោបាយថ្មី និងការរៀបចំអនុវត្តសំណើគោលនយោបាយនេះត្រូវបានបង្ហោះក្នុងខែវិច្ឆិកា ឆ្នាំ២០១៦ ដើម្បីសុំការផ្តល់មតិយោបល់ជាសាធារណៈ[1]។ ធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធខាងក្រៅក្នុងខែធ្នូ ឆ្នាំ២០១៦ និងក្នុងខែមិថុនា-កក្កដា ឆ្នាំ២០១៧ បានធ្វើការពិគ្រោះយោបល់នៅក្នុងប្រទេសចំនួន១៦ និងតំបន់ចំនួន១។[2] សេចក្តីព្រាងលើកទី២ ដែលទទួលបានតាមរយៈការពិគ្រោះយោបល់ ត្រូវបានបង្ហោះនៅលើគេហទំព័រ ក្នុងខែកុម្ភៈ ឆ្នាំ២០១៨។ ក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានពិគ្រោះយោបល់ក្នុងលក្ខណៈមិនផ្លូវការ ក្នុងខែមេសា ឆ្នាំ២០១៧ និង ខែមេសា ឆ្នាំ២០១៨។ សេចក្តីព្រាងឯកសារគោលនយោបាយមួយ ត្រូវបានផ្សព្វផ្សាយនៅក្នុងគេហទំព័រ និង ដាក់ជូនក្រុមប្រឹក្សាភិបាល ក្នុងខែកក្កដា ឆ្នាំ២០១៨។

1 ADB. 2016. *Public Communications Policy Review*. https://www.adb.org/site/disclosure/pcp-review

2 លំដាប់លំដោយនៃការពិគ្រោះយោបល់៖ បង់ក្លាដេស នេប៉ាល់ ហ្វីលីពីន តាជីគីស្ថាន ថៃ កម្ពុជា ឡាវ វៀតណាម កាណាដា សហរដ្ឋអាមេរិក អឺរ៉ុប (មកពីអាល្លឺម៉ង់) អូស្ត្រាលី ទីម័រឡេស្ត ហ្វីជី ឥណ្ឌា អាហ្សែបៃចាន និង ច័រជៀ។

៣. **ការពិនិត្យកែសម្រួលឡើងវិញ៖** ការពិនិត្យកែសម្រួលឡើងវិញទៅលើគោលនយោបាយបានបង្ហាញឱ្យដឹងថា គោលការណ៍ និង ករណីលើកលែងសម្រាប់ការបើកបង្ហាញព័ត៌មាននៃគោលនយោបាយទំនាក់ទំនងសាធារណៈមានសង្គតភាពទៅនឹងគោលការណ៍របស់ធនាគារអភិវឌ្ឍន៍ ពហុភាគី និងបណ្តាប្រទេសជាច្រើនដទៃទៀត។ ការពិនិត្យកែសម្រួលឡើងវិញនេះ ក៏បានរកឃើញផងដែរថា ធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀតកំពុងបោះជំហានងាកទៅរកគោលនយោបាយដែលមានមូលដ្ឋានផ្អែកលើគោលការណ៍ដែលបច្ចុប្បន្នត្រូវបានចាត់ទុកថាជាការអនុវត្តល្អបំផុត សម្រាប់ការបើកបង្ហាញព័ត៌មាន។ បន្ថែមពីនេះទៀត ការប៉ាន់ប្រមាណប្រចាំឆ្នាំទៅលើគោលនយោបាយទំនាក់ទំនងសាធារណៈ បានបង្ហាញឱ្យឃើញអំពីកំណើននៃចំនួនឯកសារដែលត្រូវបានបង្ហាញនៅក្នុងគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (www.adb.org)។ បើទោះជាដូច្នេះក្តី ការប៉ាន់ប្រមាណក៏បានរកឃើញផងដែរថា ការបង្ហាញឯកសារ ជួនកាលមានភាពយឺតយ៉ាវដោយសារ បុគ្គលិកមិនបានដឹងអំពីលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានជាពិសេសគឺប្រភេទផលិតផល ឬ ឯកសារដែលត្រូវបានណែនាំឱ្យស្គាល់ គិតចាប់ពីពេលដែលគោលនយោបាយទំនាក់ទំនងសាធារណៈ ត្រូវបានអនុម័តក្នុងឆ្នាំ២០១១ ប៉ុន្តែពុំមានចែងនៅក្នុងគោលនយោបាយ។

៤. ការពិនិត្យកែសម្រួលឡើងវិញនេះ ក៏បានរកឃើញផងដែរថា ដំណើរការស្នើសុំព័ត៌មាន និង ដំណើរការប្តឹងជំទាស់ ប្រព្រឹត្តទៅបានល្អ។ ក្នុងឆ្នាំ២០១៧ ធនាគារអភិវឌ្ឍន៍អាស៊ីទទួលបានសំណើសុំព័ត៌មានចំនួន ៣.៦៥៣ ដែលចំនួននេះមានការកើនឡើងយ៉ាងខ្លាំង បើធៀបទៅនឹងឆ្នាំ២០១២ ដែលចំនួនសំណើសុំព័ត៌មាន មានត្រឹមតែ ២៣០ ប៉ុណ្ណោះ។[3] ក្នុងឆ្នាំ២០១៧ ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ការបញ្ជាក់ថាបានទទួលសំណើចំនួន ៨១% ក្នុងរយៈពេល៥ថ្ងៃដែលបានកំណត់ និងបានឆ្លើយតបចំពោះសំណើចំនួន ៩៦% ក្នុងរយៈពេលកំណត់២០ថ្ងៃ។ សំណើសុំព័ត៌មានចំនួន៧ ត្រូវបានបដិសេធន៍ក្នុងចំណោមនោះមានសំណើចំនួន៦បានស្នើសុំព័ត៌មានរសើបទាក់ទងនឹងហិរញ្ញវត្ថុអំពីបញ្ហាមូលប័ត្រ។ ករណីមួយត្រូវបានប្តឹងជំទាស់ក្នុងឆ្នាំ២០១៧ ដែលដូចគ្នាទៅនឹងឆ្នាំ ២០១៦ដែរ។[4]

៥. **សំណើសុំឱ្យកែប្រែគោលនយោបាយ៖** គោលនយោបាយទំនាក់ទំនងសាធារណៈ ប្រើប្រាស់អភិក្រមដែលមានមូលដ្ឋានផ្អែកលើវិធានមួយ សម្រាប់ធ្វើការបង្ហាញព័ត៌មាន។ វាផ្តល់នូវគោលការណ៍ណែនាំលម្អិត ដែលមានគោលបំណងចាប់យកនូវករណី និងស្ថានភាពដែលងាយស្រួលបំផុតក្នុងការព្យាករណ៍ទុកជាមុន ជាមួយនឹងករណីលើកលែងចំពោះការបង្ហាញព័ត៌មាន និងពេលវេលា ដែលត្រូវបានកំណត់ទុកជាមុន និង

3 ADB. 2017. *Public Communications Policy Annual Report 2017*. https://www.adb.org/sites/default/files/institutional-document/424291/pcp-annual-report-2017.pdf

4 https://www.adb.org/site/disclosure/pcp-implementation/appeals/appeals-received

មានការចែងយ៉ាងតឹងរឹង។ គោលនយោបាយដែលមានមូលដ្ឋានផ្អែកលើវិធានគ្រប់គ្រងទៅលើការបង្ហាញព័ត៌មាន តាមរយៈអភិក្រមមួយដែលគ្មានភាពបត់បែនទន់ភ្លន់ចំពោះការចែករំលែកព័ត៌មាន។ បើទោះជាដូច្នេះក្តី ធុរកិច្ចរបស់ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងមានការផ្លាស់ប្តូរ អាស្រ័យដោយធនាគារអភិវឌ្ឍន៍អាស៊ីសម្របខ្លួនទៅតាមសេចក្តីត្រូវការរបស់តំបន់ដែលកំពុងមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ គោលនយោបាយស្តីពីការបង្ហាញព័ត៌មានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវមានភាពស្របគ្នាទៅនឹងការវិវឌ្ឍន៍ដ៏ឆាប់រហ័សនេះ។អភិក្រមដែលមានមូលដ្ឋានផ្អែកលើវិធានរមែងតែងគ្មានភាពបត់បែនទន់ភ្លន់ ក្នុងការសម្របខ្លួនឱ្យបានឆាប់រហ័សទៅនឹងការប្រែប្រួលនានា។ ចំណុចនេះ ជួនកាលបង្កឱ្យមានលទ្ធផលដែលគ្មាន សង្គតភាពទៅនឹងគោលបំណងនៃគោលនយោបាយដែលគេចង់បាន ដែលនោះគឺជាការសន្និដ្ឋាន ជាមុនថានឹងមានការបង្ហាញ និងការចែករំលែកព័ត៌មានទាន់ពេលវេលាគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធផ្តល់ធាតុចូល និងយោបល់ត្រឡប់ប្រកបដោយអត្ថន័យ។

៦. ដូច្នេះ យោងតាមស្ថាប័នប្រហាក់ប្រហែលដទៃទៀត ធនាគារអភិវឌ្ឍន៍អាស៊ីស្នើឱ្យមានក្របខ័ណ្ឌគោលនយោបាយស្តីពីការបង្ហាញព័ត៌មានដែលបែងចែកជាពីរផ្នែក៖ (១) គោលនយោបាយមានមូលដ្ឋានផ្អែកលើគោលការណ៍ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចមានកំណត់ចែងនៅក្នុងឯកសារនេះ និង (២) ការរៀបចំអនុវត្តលម្អិតដែលអនុម័តដោយថ្នាក់គ្រប់គ្រង និង ផ្សព្វផ្សាយជាសាធារណៈនៅក្នុង*សៀវភៅណែនាំស្តីពីប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី* ស្របតាមនីតិវិធីប្រក្រតីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

៧. អភិក្រមដែលមានមូលដ្ឋានផ្អែកលើគោលការណ៍មួយប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានគោលការណ៍ច្បាស់លាស់ និងការប្រាស្រ័យទាក់ទងបែបប្រតិសកម្ម និងបែបសហការ រវាងធនាគារអភិវឌ្ឍន៍អាស៊ី និងអ្នកពាក់ព័ន្ធរបស់ខ្លួន។ វាក៏ទាមទារឱ្យមានការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹងជាទៀងទាត់ សម្រាប់បុគ្គលិកនិងដៃគូ ព្រមទាំងដំណើរការប្តឹងជំទាស់មួយច្បាស់លាស់ផងដែរ ដើម្បីធានាថាគោលការណ៍ត្រូវបានយកមកអនុវត្តត្រឹមត្រូវ ប្រកបដោយសង្គតភាព និងភាពសុចរិត។ ការត្រួតពិនិត្យ និងរាយការណ៍ឱ្យបានសកម្ម រួមទាំងការរាយការណ៍ជូនក្រុមប្រឹក្សាភិបាលក៏មានសារៈសំខាន់ផងដែរ ដើម្បីធានាថាគោលការណ៍គោលនយោបាយ កំពុងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និង សង្គតភាព។ គោលនយោបាយ ការរៀបចំអនុវត្តនិងរបាយការណ៍ត្រួតពិនិត្យ ព្រមទាំងព័ត៌មានពាក់ព័ន្ធដទៃទៀត នឹងបន្តផ្តល់ជូនតាមរយៈគេហទំព័រទោលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។[5]

5 https://www.adb.org/site/disclosure/main

៨. គោលនយោបាយដែលបានស្នើឡើង ផ្តោតយកចិត្តទុកដាក់សំខាន់លើគោលការណ៍ និងដឹកនាំដោយគោលការណ៍រួមថ្មីមួយ ស្តីពី "ការបង្ហាញព័ត៌មានច្បាស់លាស់ ទាន់ពេលវេលា និងសមស្រប"។ គោលការណ៍ដទៃទៀត ភាគច្រើនពុំមានការប្រែប្រួលពីគោលនយោបាយទំនាក់ទំនងសាធារណៈឡើយ និង មានការគាំទ្រពីការសន្និដ្ឋានជាមុនដែលមាននិន្នាការងាកទៅរកការបង្ហាញព័ត៌មានដែលមានករណីលើកលែងតិចតួច។ តទៅមុខទៀត ខណៈពេលដែលគោលការណ៍នៃគោលនយោបាយនៅតែបន្តជាធរមានរហូតដល់មានការផ្លាស់ប្តូរពីក្រុមប្រឹក្សាភិបាល ឧទាហរណ៍ដូចជា ការរៀបចំអនុវត្តអាចត្រូវបានធ្វើបច្ចុប្បន្នភាពទៅតាមភាពចាំបាច់ ដើម្បីឆ្លុះបញ្ចាំងអំពីផលិតផល ឬ ដំណើរការថ្មីៗ ដោយមានការអនុម័តពីថ្នាក់គ្រប់គ្រងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការផ្លាស់ប្តូរនេះគួរធានាឱ្យបាននូវភាពច្បាស់លាស់ចំពោះការអនុវត្ត និង លទ្ធភាពក្នុងការព្យាករណ៍អំពីការបង្ហាញព័ត៌មាន។ ការផ្តល់គោលការណ៍ណែនាំប្រកបដោយបច្ចុប្បន្នភាព អំពីប្រភេទឯកសារ និង ពេលដែលឯកសារត្រូវបង្ហាញជាទៀងទាត់ មានគោលបំណងជួយដល់ធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការកែលម្អចំពោះការបង្ហាញព័ត៌មានឱ្យបានទាន់ពេលវេលា និង ប្រសិទ្ធភាពគោលនយោបាយ។ ពាក់ព័ន្ធនឹងការបង្ហាញរបាយការណ៍វាយតម្លៃឯករាជ្យ ការរៀបចំអនុវត្ត ឆ្លុះបញ្ចាំងការអនុវត្តបច្ចុប្បន្នអំពីការបង្ហាញរបាយការណ៍ដែលបានបញ្ចប់រួចរាល់[6] ឬ ការរៀបចំដទៃទៀតដែលអាចមានភាពចាំបាច់នៅក្នុងគោលនយោបាយណាមួយនៅពេលអនាគតដែលអនុម័តដោយក្រុមប្រឹក្សាភិបាល និង ដែលគ្របដណ្តប់ទៅលើនាយកដ្ឋានវាយតម្លៃឯករាជ្យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

៩. សំណើឱ្យមានការកែប្រែដ៏ទៃទៀតពីគោលនយោបាយទំនាក់ទំនងសាធារណៈ រួមមានការដកចេញនូវផ្នែកព័ត៌មានសារតា ដែលលែងមានបច្ចុប្បន្នភាព និង ផ្នែកទំនាក់ទំនងសាធារណៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ អភិក្រមទំនាក់ទំនងសាធារណៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ី រៀបរាប់អំពី ការអនុវត្តទំនាក់ទំនងស្ថាប័នរបស់ធនាគារនេះ។ អភិក្រមទំនាក់ទំនង អាចប្រែប្រួលយ៉ាងឆាប់រហ័ស ខណៈពេលដែលមានការលេចចេញនូវចរន្តទំនាក់ទំនងថ្មី និង ជនគោលដៅមានការវិវឌ្ឍន៍។ អាស្រ័យដោយសកម្មភាពទាំងនេះមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ពីសកម្មភាពបង្ហាញព័ត៌មាន ដូច្នេះ សកម្មភាពទាំងនេះនឹងត្រូវបានពណ៌នានៅក្នុងឯកសារដោយឡែកមួយ ព្រមទាំងនឹងផ្តល់ជូនតាមរយៈគេហទំព័រស្តីពីការទទួលបានព័ត៌មានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (កំណត់សម្គាល់នៅជើងទំព័រទី៥)។

---

6 ស្ថិតក្រោមការអនុវត្តបច្ចុប្បន្ន រាល់របាយការណ៍វាយតម្លៃឯករាជ្យទាំងអស់ ត្រូវបានបោះពុម្ពផ្សាយក្នុងរយៈពេល ១៤ថ្ងៃ ក្រោយពេលបញ្ចប់ និង ចែកជូនថ្នាក់គ្រប់គ្រង ព្រមទាំងក្រុមប្រឹក្សាភិបាល លើកលែងតែរបាយការណ៍ត្រួតពិនិត្យការវាយតម្លៃប្រចាំឆ្នាំរបស់នាយកដ្ឋានវាយតម្លៃឯករាជ្យ ដែលត្រូវបានបង្ហាញក្នុងរយៈពេល១៤ថ្ងៃ ក្រោយពេលពិភាក្សាជាមួយក្រុមប្រឹក្សាភិបាល។

១០. ដើម្បីកែលម្អគោលនយោបាយទំនាក់ទំនងសាធារណៈ គោលនយោបាយនេះត្រូវបានប្តូរឈ្មោះទៅជាគោលនយោបាយស្តីពីការទទួលបានព័ត៌មាន (AIP)។ ចំណងជើងថ្មីនេះ ផ្តល់នូវសេចក្តីពណ៌នាកាន់តែច្បាស់អំពីការផ្តោតយកចិត្តទុកដាក់កាន់តែខ្លាំងនៃគោលបំណងស្តីពីការបង្ហាញព័ត៌មាន និង ការផ្តល់ព័ត៌មានរបស់គោលនយោបាយនេះ។ ការផ្លាស់ប្តូរចំណងជើងនេះ មានភាពស្របគ្នាទៅនឹងធនាគារអភិវឌ្ឍន៍ដទៃទៀត ជាពិសេសគឺបណ្តាធនាគារដែលមានគោលនយោបាយផ្តោតលើគោលការណ៍។

១១. ផ្អែកលើមតិយោបល់ដែលបានទទួលទៅលើសេចក្តីព្រាងសម្រាប់ពិគ្រោះយោបល់លើកទី១ និងលើកទី២ និង សេចក្តីព្រាងឯកសារ ឯកសារពិនិត្យកែសម្រួលឡើងវិញនេះ ត្រូវបានអភិវឌ្ឍឡើង សម្រាប់ក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការពិចារណា។ ប្រសិនបើទទួលបានការអនុម័ត គោលនយោបាយថ្មីនេះនឹងចូលជាធរមាននៅថ្ងៃទី ១ ខែមករា ឆ្នាំ២០១៩។ ការរៀបចំ អនុវត្តនឹងត្រូវអនុម័តដោយថ្នាក់គ្រប់គ្រងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងចូលជាធរមានក្នុងពេលដំណាលគ្នាទៅនឹងគោលនយោបាយនេះដែរ។

១២. **ធនធាន៖** ថវិកាបឋមសម្រាប់ការផ្សព្វផ្សាយខាងក្នុង និងខាងក្រៅ ការលើកកម្ពស់ការយល់ដឹង ការបកប្រែភាសា និងការបណ្តុះបណ្តាលបុគ្គលិក ត្រូវបានវិភាជន៍ដើម្បីធានាថាការផ្សព្វផ្សាយដាក់ឱ្យអនុវត្តគោលនយោបាយស្តីពីការទទួលបានព័ត៌មានថ្មីនេះ ប្រព្រឹត្តទៅដោយរលូន។ ការិយាល័យលេខា នឹងទទួលខុសត្រូវទាំងស្រុងសម្រាប់ការអនុវត្តគោលនយោបាយស្តីពីការទទួលបានព័ត៌មាននេះ។ មុខតំណែងបន្ថែមចំនួនពីរទៀតសម្រាប់បុគ្គលិក រួមមានមុខតំណែងមួយសម្រាប់បុគ្គលិកអន្តរជាតិ និងមុខតំណែងមួយទៀតសម្រាប់បុគ្គលិកជាតិ ត្រូវបានកំណត់ និង បែងចែកដើម្បីឱ្យទទួលបន្ទុកគោលនយោបាយស្តីពីការទទួលបានព័ត៌មាននេះ។ តម្រូវការធនធានបន្ថែមទៀតសម្រាប់ការអនុវត្តគោលនយោបាយស្តីពីការទទួលបានព័ត៌មាន នឹងទទួលបានការបញ្ជាក់ក្នុងអំឡុងពេលរៀបចំថវិកាប្រចាំឆ្នាំ និងដំណើរការវិភាគថវិកា។

# II. ការណែនាំអំពីគោលនយោបាយនេះ

១៣.គោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាន មានគោលបំណងលើកកម្ពស់ការជឿទុកចិត្តរបស់ភាគីពាក់ព័ន្ធនានា មកលើធនាគារអភិវឌ្ឍន៍អាស៊ី (ហៅកាត់ថា ADB) និងដើម្បីបង្កើនផលប៉ះពាល់វិជ្ជមានលើការអភិវឌ្ឍន៍ ដែលបានពីការគាំទ្ររបស់ ADB។ គោលនយោបាយនេះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ ADB ដើម្បីលើកកម្ពស់តម្លាភាព គណនេយ្យភាព និងការចូលរួមរបស់ភាគីពាក់ព័ន្ធនានា ក្នុងសកម្មភាពអភិវឌ្ឍន៍ ដែលទទួលបានការគាំទ្រពី ADB នៅអាស៊ី និងប៉ាស៊ីហ្វិក។ គោលនយោបាយនេះ ក៏បានទទួលស្គាល់ពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការស្វែងរកព័ត៌មាន ទទួលបានព័ត៌មាន និងផ្តល់ព័ត៌មានអំពីប្រតិបត្តិការរបស់ ADB ផងដែរ។

១៤. គោលនយោបាយនេះ អនុវត្តចំពោះឯកសារ និងព័ត៌មានដែល ADB ផលិត ឬដែលអ្នកខ្ចី ឬអតិថិជនរបស់ខ្លួនតម្រូវឱ្យផលិត ឬឯកសារដែលត្រូវបានភាគីផ្សេងទៀតផលិត និងផ្តល់ឱ្យ ADB ក្នុងអំឡុងប្រតិបត្តិការរបស់ ADB។ គោលនយោបាយនេះ ត្រូវអនុវត្តស្របទៅតាមការរៀបចំដែលបានឯកភាពពីអ្នកគ្រប់គ្រងរបស់ ADB និងត្រូវផ្សព្វផ្សាយជាសាធារណៈ ស្របតាមនីតិវិធីទូទៅរបស់ ADB។[7]

7 ការរៀបចំការអនុវត្តគោលនយោបាយនានារបស់ ADB មានចែងក្នុងនីតិវិធីប្រតិបត្តិការក្នុងសៀវភៅណែនាំស្តីពីប្រតិបត្តិការ របស់ ADB (ដូចដែលមានការកែសម្រួលជាបន្តបន្ទាប់)។

# III. គោលការណ៍ និងករណីលើកលែង នៃគោលនយោបាយនេះ

## ក. គោលការណ៍នៃគោលនយោបាយ

១៥. គោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាន ត្រូវបានរៀបចំឡើងផ្អែកតាមគោលការណ៍ដូចខាងក្រោម៖

(i) **ការបង្ហាញព័ត៌មានច្បាស់លាស់ ទាន់ពេលវេលា និងសមស្រប។** ADB បង្ហាញព័ត៌មានអំពី ប្រតិបត្តិការរបស់ខ្លួន ប្រកបដោយភាពច្បាស់លាស់ ទាន់ពេលវេលា និងសមស្រប ដើម្បីឱ្យភាគី ពាក់ព័ន្ធនានា អាចចូលរួមជាមួយ ADB បានកាន់តែច្រើន និងប្រកបដោយអត្ថន័យ និងដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ។

(ii) **ការសន្មតជាមុន ដែលលម្អៀងទៅរកការបង្ហាញព័ត៌មាន។** ADB បង្ហាញព័ត៌មានលើកលែងតែ ព័ត៌មានដែលស្ថិតក្នុងប្រភេទករណីលែកលែង ដូចបញ្ជាក់ក្នុងឯកសារគោលនយោបាយនេះ។

(iii) **ករណីលើកលែងមានកំណត់។** ការបង្ហាញព័ត៌មានទាំងស្រុង មែនមែនអាចធ្វើទៅបានជានិច្ចនោះឡើយ។ ឧទាហរណ៍ ADB ចាំបាច់ត្រូវស្វែងយល់ពីគំនិតផ្សេងៗ ចែករំលែកព័ត៌មាន ពិភាក្សាត្រង់ទៅត្រង់មក និងជជែកវែកញែកពីគំនិតផ្សេងៗ ដោយសេរី ទាំងផ្ទៃក្នុងរបស់ធនាគារ និងជាមួយសមាជិក ឬអតិថិជនរបស់ខ្លួន។ ក្នុងករណីផ្សេងទៀត ADB ចាំបាច់ត្រូវពិចារណាពីលក្ខខណ្ឌពិសេសៗនៃប្រតិបត្តិការមិនមែនរដ្ឋ និងលក្ខខណ្ឌដែលកំណត់ដោយអតិថិជនរបស់ខ្លួន[8] ការពារសិទ្ធិភាពជាឯកជនរបស់បុគ្គលិក ឬការពារផលប្រយោជន៍ធុរកិច្ចរបស់ធនាគារ និងរបស់អតិថិជនរបស់ខ្លួន។ គោលនយោបាយនេះ ចែងពីករណីលើកលែងមួយចំនួនតូច ដែលថ្លឹងថ្លែងរវាងសិទ្ធិ និងផលប្រយោជន៍របស់ភាគីផ្សេងៗ។ យ៉ាងណាក៏ដោយ ក្នុងកាលៈទេសៈពិសេសៗមួយចំនួន ADB រក្សាសិទ្ធិក្នុងការសម្រេចចិត្តផ្ទុយពីករណីលើកលែងក្នុងគោលនយោបាយនេះ (កថាខណ្ឌទី ៦) ឬមិនធ្វើការបង្ហាញព័ត៌មាន ដែលធនាគារធ្លាប់តែបង្ហាញជាធម្មតា (កថាខណ្ឌទី៧)។

(iv) **ការផ្តួចផ្តើមបង្ហាញព័ត៌មាន។** ADB ផ្តួចផ្តើមចែករំលែកឯកសារចំណេះដឹង និងព័ត៌មានអំពី ប្រតិបត្តិការរបស់ខ្លួនឱ្យបានទាន់ពេលវេលា ដើម្បីសម្រួលដល់ការចូលរួមធ្វើសេចក្តីសម្រេចចិត្តជាមួយ ADB។ ខណៈពេលដែលវិបសាយរបស់ ADB នៅតែជាមធ្យោបាយចម្បងសម្រាប់ផ្តួចផ្តើមបង្ហាញព័ត៌មានបែបនេះ ADB ក៏ប្រើប្រាស់មធ្យោបាយសមស្របផ្សេងទៀត ដើម្បីបង្ហាញ និងផ្សព្វផ្សាយព័ត៌មានផងដែរ។

8 កិច្ចព្រមព្រៀងចងកាតព្វកិច្ចផ្លូវច្បាប់ មិនបង្ហាញព័ត៌មានធុរកិច្ចសម្ងាត់របស់អតិថិជន គឺជាលក្ខខណ្ឌស្តង់ដារមួយសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុវិស័យឯកជន ក៏ដូចជាស្ថាប័នប្រហាក់ប្រហែលនឹង ADB ផ្សេងទៀត នៅពេលចូលរួមធ្វើធុរកិច្ចជាមួយនឹងអតិថិជន។ ភាពចាំបាច់ក្នុងការការពារព័ត៌មានធុរកិច្ចសម្ងាត់ ក៏ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយក្នុងច្បាប់ស្តីពីសេរីភាពព័ត៌មានដែលមានបញ្ចូលពីករណីលើកលែងមិនឱ្យមានការបញ្ចេញព័ត៌មានពាណិជ្ជកម្ម ដែលមានលក្ខណៈជាព័ត៌មានសម្ងាត់។

(v) **ការចែករំលែកព័ត៌មាន និងគំនិត។** គោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាន ចែងពីដំណើរការដែលភាគីពាក់ព័ន្ធនានាអាចស្វែងរក ទទួលបាន និងបញ្ជូនព័ត៌មាន និងគំនិតនានា អំពីប្រតិបត្តិការរបស់ ADB ដោយស្មើភាពគ្នា។ ទំនាក់ទំនង និងការផ្លាស់ប្តូរព័ត៌មាន និងគំនិតប្រកបដោយប្រសិទ្ធិភាពជាមួយនឹងភាគីពាក់ព័ន្ធនានា គឺជាសមាសភាគដ៏សំខាន់នៃការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងចីរភាព។

(vi) **ការផ្តល់ព័ត៌មាន ដល់អ្នករងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធដទៃទៀត។** ADB សហការយ៉ាងជិតស្និទ្ធជាមួយនឹងអ្នកខ្ចី និងអតិថិជនរបស់ខ្លួន ដើម្បីធានាឱ្យមានការប្រាស្រ័យទាក់ទងទ្វេទិសជាមួយនឹងអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីផ្សេងទៀតអំពីគម្រោងរបស់ ADB។ ការប្រាស្រ័យទាក់ទងបែបនេះ ធ្វើឡើងដោយមានការកំណត់ពីពេលវេលាច្បាស់លាស់ ប្រើប្រាស់ភាសាដែលពាក់ព័ន្ធ[9] និងតាមបែបផែនដែលអនុញ្ញាតឱ្យជនរងផលប៉ះពាល់ដោយសារគម្រោង និងអ្នកពាក់ព័ន្ធផ្សេងទៀត អាចផ្តល់ធាតុចូលប្រកបដោយអត្ថន័យ ក្នុងការរៀបចំ និងការអនុវត្តគម្រោង។

(vii) **ភាពជាម្ចាស់របស់ប្រទេស និងអតិថិជន។** អ្នកខ្ចី និងអតិថិជនរបស់ ADB គឺជាម្ចាស់គម្រោងដែល ADB ផ្តល់ការគាំទ្រ ឬដែលធនាគារនេះដាក់ទុនវិនិយោគ។ ដូច្នេះ ក្នុងករណីមួយចំនួន មានការពិចារណាលើការយល់ឃើញរបស់អ្នកខ្ចី និងអតិថិជនពាក់ព័ន្ធនឹងខ្លឹមសារ និងពេលវេលានៃការបង្ហាញឯកសារ មុនពេលផ្សព្វផ្សាយឯកសារទាំងនេះ។

(viii) **ដំណើរការសាទុក្ខមានភាពច្បាស់លាស់។** ដំណើរការច្បាស់លាស់ សម្រាប់ដាក់បណ្តឹងសាទុក្ខជំទាស់នឹងការសម្រេចចិត្តរបស់ ADB ដែលមិនបង្ហាញព័ត៌មានតាមការស្នើសុំ គឺជាផ្នែកមួយដ៏សំខាន់នៃក្របខ័ណ្ឌបង្ហាញព័ត៌មានប្រកបដោយអត្ថន័យ។

(ix) **ការពិនិត្យតាមដានជាប់ជាប្រចាំ។** ADB ពិនិត្យតាមដានលើប្រសិទ្ធភាពនៃគោលនយោបាយនេះ ប្រមូលមេរៀនដែលទទួលបានពីភាពជោគជ័យ និងចំណុចខ្វះខាតរបស់ខ្លួន និងខិតខំប្រើប្រាស់បច្ចេកវិទ្យា និងការអនុវត្តថ្មីៗ។

## ខ. ករណីលើកលែងចំពោះការបង្ហាញព័ត៌មាន

១៦. ADB បង្ហាញព័ត៌មានដែលខ្លួនមាន ហើយដែលមិនស្ថិតក្រោមករណីលើកលែង ដូចចែងក្នុងគោលនយោបាយនេះ។ ករណីលើកលែងទាំងនេះ ត្រូវបានរៀបចំឡើង ផ្អែកតាមការសម្រេចចិត្តរបស់ ADB ដែលកំណត់ថា ការបង្ហាញប្រភេទព័ត៌មានមួយចំនួន អាចបង្កផលប៉ះពាល់ដល់ភាគី ឬផលប្រយោជន៍ លើសពីអត្ថប្រយោជន៍ដែលទទួលបានពីការបង្ហាញព័ត៌មានទាំងនេះ។ ការវាយតម្លៃលើផលប៉ះពាល់-ផលប្រយោជន៍នៃការបង្ហាញព័ត៌មាន គឺជាដំណើរការថ្លឹងថ្លែងពីផលប៉ះពាល់ ដែលទំនងជានឹងកើតមានឡើង

9 គោលការណ៍ណែនាំស្តីពីការបកប្រែរបស់ ADB អនុញ្ញាតឱ្យគេបកប្រែឯកសារនានាជាភាសាផ្លូវការ និងភាសាជាតិ។ ភាសាដែលប្រើប្រាស់នៅតាមមូលដ្ឋាន អាចត្រូវបានប្រើប្រាស់ទៅតាមករណីជាក់ស្តែង ទៅតាមការកំណត់របស់ការិយាល័យប្រចាំប្រទេស។

ចេញពីការបង្ហាញព័ត៌មាននេះ ធៀបនឹងផលប្រយោជន៍សរុបដែលទទួលបានពីការបង្ហាញព័ត៌មាននេះ។ ក្នុងបរិបទនៃគោលការណ៍សម្រាប់ការបង្ហាញព័ត៌មានរបស់ ADB (កថាខណ្ឌទី ៣) ជាពិសេស គោលការណ៍សន្មតជាមុនដែលលម្អៀងទៅរកការបង្ហាញព័ត៌មាន ការវាយតម្លៃ និងមូលហេតុដែលនាំឱ្យមិនមានការបង្ហាញព័ត៌មានបែបនេះ ត្រូវបានកំហិតត្រឹមតែប្រភេទព័ត៌មានដែលរៀបរាប់ក្នុងកថាខណ្ឌទី ៥ តែប៉ុណ្ណោះ។ ប្រសិនបើឯកសារ ឬផ្នែកណាមួយនៃឯកសារ មិនត្រូវបង្ហាញ ព្រោះ ឯកសារឬផ្នែកនៃឯកសារនោះមានផ្ទុកព័ត៌មានដែលស្ថិតក្រោមករណីលើកលែងមួយ ឬច្រើន ក្នុងគោលនយោបាយនេះ ADB នឹងលើកឡើងពីករណីលើកលែងមិនបង្ហាញព័ត៌មានទាំងនេះ។

១៧. យោងតាមប្បញ្ញត្តិក្នុងគោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាន ពាក់ព័ន្ធនឹងការសម្រេចចិត្តផ្ទុយនឹងប្បញ្ញត្តិក្នុងគោលនយោបាយនេះ (កថាខណ្ឌទី ៦) ព័ត៌មាន ឬឯកសារដែលឋិតក្នុងប្រភេទខាងក្រោមនេះ ពុំត្រូវបានបង្ហាញឡើយ៖

### ១. ដំណើរការពិភាក្សា និងធ្វើការសម្រេចចិត្ត

ព័ត៌មាន ដែលជាមូលដ្ឋានសម្រាប់ដំណើរការពិភាក្សា ឬធ្វើសេចក្តីសម្រេចចិត្តរបស់ ADB ជាទូទៅ ត្រូវបានលើកលែងពីការបង្ហាញ។ ករណីលើកលែងប្រភេទនេះ ធ្វើឡើងផ្អែកតាមគោលការណ៍ដែលថា ការពិភាក្សាជជែកវែកញែក និងការផ្តល់ដំបូន្មានសម្រាប់ធ្វើការសម្រេចចិត្តអ្វីមួយ ត្រូវធ្វើឡើងដោយសេរី និងដោយត្រង់ទៅត្រង់មក។ ករណីលើកលែងនេះ គ្របដណ្តប់លើព័ត៌មានដូចខាងក្រោម៖

(i) ប្រសិនបើបង្ហាញ ព័ត៌មានផ្ទៃក្នុងនោះ នឹងឬទំនងជានឹងធ្វើឱ្យប៉ះពាល់ដល់បូរណភាពនៃដំណើរការពិភាក្សា និងដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ ADB ដោយបន្ទុចបង្អាក់មិនឱ្យមានការផ្លោះប្តូរត្រង់ទៅត្រង់មកនូវគំនិត ការយល់ឃើញ និងការប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ដែលបង្កផលប៉ះពាល់អវិជ្ជមានលើគុណភាពនៃការសម្រេចចិត្ត និងលទ្ធផល សម្រាប់ ADB និងភាគីពាក់ព័ន្ធរបស់ធនាគារនេះ។ ឧទាហរណ៍នៃព័ត៌មានប្រភេទនេះ មានដូចជា ដំបូន្មាន និងគំនិតដែលផ្លោះប្តូររវាងសមាជិកក្រុមប្រឹក្សាភិបាល ទីប្រឹក្សារបស់នាយក សមាជិកនៃគណៈគ្រប់គ្រង បុគ្គលិករបស់ ADB និងទីប្រឹក្សា ADB ដែលមានលក្ខណៈជាការជជែកពិភាក្សាគ្នាទូទៅ។ ខណៈពេលដែល ជាធម្មតា ADB ធ្វើការបង្ហាញព័ត៌មានអំពីលទ្ធផលនៃដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ខ្លួន ADB អាចមិនធ្វើការបង្ហាញគ្រប់គំនិតទស្សនៈយល់ឃើញ និងវិធីសាស្ត្រទាំងអស់ដែលត្រូវបានប្រើប្រាស់ មុននឹងឈានដល់ការធ្វើសេចក្តីសម្រេចចិត្តទាំងនោះឡើយ ព្រោះថាភាគីពាក់ព័ន្ធនានាចាំបាច់ត្រូវបង្ហាញ និងជជែកវែកញែកគំនិតទស្សនៈយល់ឃើញ និងវិធីសាស្ត្រទាំងនេះ ដោយសេរី។

(ii) កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល[10] លើកលែងតែឯកសាររបស់ក្រុមប្រឹក្សាភិបាល[11] អត្ថបទប្រតិចារឹកដែលកត់ត្រាគ្រប់ពាក្យដែលនិយាយ (verbatim transcript)[12] កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល[13] និងរបាយការណ៍សង្ខេបរបស់ប្រធានកិច្ចប្រជុំមួយចំនួនរបស់ក្រុមប្រឹក្សាភិបាល[14] ព្រោះថាការបង្ហាញព័ត៌មានទាំងនេះ នឹងបន្ថយចបង្អាក់មិនឱ្យមានការផ្លោះប្តូរគំនិតទស្សនៈយល់ឃើញ និងវិធីសាស្ត្រផ្សេងៗត្រង់ទៅត្រង់មក រវាងសមាជិកក្រុមប្រឹក្សាភិបាល។

(iii) ព័ត៌មានដែលត្រូវបានផ្លោះប្តូរ ដែលរៀបចំសម្រាប់ ឬយកចេញពីដំណើរការពិភាក្សា និង ធ្វើសេចក្តីសម្រេចចិត្តរវាង ADB និងសមាជិករបស់ធនាគារនេះ និងស្ថាប័នដទៃទៀត ដែល ADB សហការជាមួយ។ ប្រសិនបើបង្ហាញព័ត៌មាននេះនឹង ឬទំនងជាធ្វើឱ្យប៉ះពាល់ដល់បូរណភាពនៃដំណើរការពិភាក្សា និងធ្វើសេចក្តីសម្រេចចិត្តរបស់ ADB និងសមាជិករបស់ខ្លួន ឬស្ថាប័នដទៃទៀត ដែល ADB សហការជាមួយ ព្រោះថាវានឹងនាំឱ្យមានការបន្ថយចបង្អាក់ ដល់ការផ្លោះប្តូរគំនិតទស្សនៈយល់ឃើញ និងវិធីសាស្ត្រនានាត្រង់ទៅត្រង់មក។

## ២. ព័ត៌មានដែលផ្តល់ឱ្យដោយមានការរក្សាការសម្ងាត់

(iv) ព័ត៌មានដែលសមាជិក ឬភាគីផ្សេងទៀតផ្តល់ឱ្យ ADB ដោយតម្រូវឱ្យមានការរក្សាការសម្ងាត់។ ADB មានកាតព្វកិច្ចការពារព័ត៌មាននេះ និងមិនអាចបង្ហាញព័ត៌មាននេះ

10 យោងតាមផ្នែកទី ៩ នៃវិធាននីតិវិធីរបស់ក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល គឺជាព័ត៌មានសម្ងាត់។ សម្រាប់គោលបំណងនៃគោលនយោបាយនេះ ពាក្យថាកំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល សំដៅលើឯកសារ ឬព័ត៌មានទាំងឡាយណាដែលត្រូវបានបង្កើតឡើងសម្រាប់ ឬក្នុងកិច្ចប្រជុំ និងការពិភាក្សារបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាល និងមានដូចជាឯកសាររបស់ក្រុមប្រឹក្សាភិបាល (Board paper) (ឯកសារដែលត្រូវបានចែកជូនក្រុមប្រឹក្សាភិបាលសម្រាប់ជាព័ត៌មានសម្រាប់ការពិភាក្សា ឬការពិចារណា) និងកំណត់ត្រារបស់ក្រុមប្រឹក្សាភិបាល ដូចជាសេចក្តីថ្លែងការណ៍ដែលធ្វើឡើងក្នុងអំឡុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ឬកិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិចារឹកដែលកត់ត្រាគ្រប់ពាក្យដែលនិយាយ (verbatim transcript) កំណត់ហេតុ និង/ឬកំណត់ហេតុសង្ខេបរបស់ប្រធានកិច្ចប្រជុំ គណៈកម្មាធិការ និងអនុស្សរណៈ ឬលិខិតទំនាក់ទំនងផ្សេងទៀតរវាងអ្នកគ្រប់គ្រងរបស់ ADB នាយកដ្ឋាន ឬលេខាធិការនៃក្រុមប្រឹក្សាភិបាល គណៈកម្មាធិការ ក្រុមប្រឹក្សាភិបាល និង/ឬ ការិយាល័យនាយកប្រតិបត្តិក្នុងរាល់ទម្រង់ទាំងអស់ រាប់បញ្ចូលទាំងទម្រង់អេឡិចត្រូនិចផងដែរ។

11 លើកលែងតែមានការកំហិតដោយករណីលើកលែងក្នុងគោលនយោបាយនេះ ឯកសារដែលចែកជូនក្រុមប្រឹក្សាភិបាលជ្រាបជាព័ត៌មាន ត្រូវបានបង្ហោះលើវិបសាយ បន្ទាប់ពីបានចែកជូនដល់ក្រុមប្រឹក្សាភិបាលរួច។ ឯកសារដែលត្រូវបានចែកជូនក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការពិចារណា ជាទូទៅ ត្រូវបានបង្ហាញបន្ទាប់ពីមានការអនុម័ត ឬឯកភាពពីក្រុមប្រឹក្សាភិបាលរួច។

12 ប្រតិចារឹកដែលកត់ត្រាគ្រប់ពាក្យនិយាយ (Verbatim transcript) នៃកិច្ចប្រជុំផ្លូវការរបស់ក្រុមប្រឹក្សាភិបាលអាចបង្ហាញ តាមការស្នើសុំ និងបង្ហាញទាំងស្រុង ១០ ឆ្នាំ ចាប់គិតពីថ្ងៃខែបង្កើតឯកសារទាំងនេះ ដរាបណាកិច្ចប្រជុំផ្លូវការរបស់ក្រុមប្រឹក្សាភិបាលត្រូវបានរៀបចំឡើងនូវថ្ងៃទី ឬក្រោយថ្ងៃទី ២ ខែមេសា ឆ្នាំ ២០១២ ហើយដែលគណៈកម្មាធិការទទួលបន្ទុកសិទ្ធិទទួលបានព័ត៌មានសម្រេចថា ប្រតិចារឹកទាំងនេះ ពុំមាន ឬពុំបានលើកឡើងព័ត៌មានទាំងឡាយណាដែលស្ថិតក្នុងប្រភេទករណីលើកលែងដែលមានចែងក្នុងគោលនយោបាយនេះ។

13 កំណត់ហេតុនៃកិច្ចប្រជុំទៀងទាត់នីមួយៗ របស់ក្រុមប្រឹក្សាភិបាល ត្រូវបានបង្ហាញបន្ទាប់ពីក្រុមប្រឹក្សាភិបាលបានអនុម័តលើកំណត់ហេតុទាំងនោះ និងមិនលើសពី ៦០ ថ្ងៃប្រតិទិន បន្ទាប់ពីកិច្ចប្រជុំដំបូងរបស់ក្រុមប្រឹក្សាភិបាល។ ការកំណត់នេះ អនុវត្តចំពោះកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាភិបាលដែលធ្វើឡើងនៅថ្ងៃ ឬក្រោយថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០០៥។

14 កំណត់ហេតុសង្ខេបនៃប្រធានកិច្ចប្រពុំពិភាក្សានីមួយៗរបស់ក្រុមប្រឹក្សាភិបាល អំពីយុទ្ធសាស្ត្រភាពជាដៃគូប្រចាំប្រទេស និងយុទ្ធសាស្ត្រ សហប្រតិបត្តិការថ្នាក់តំបន់ និងគោលនយោបាយ ឬយុទ្ធសាស្ត្រនីមួយៗ ដែលត្រូវបានឯកភាព ឬយល់ព្រមដោយក្រុមប្រឹក្សាភិបាលក្នុងកិច្ចប្រជុំផ្លូវការរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានបង្ហាញក្នុងអំឡុងរយៈពេល ១៤ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចែកឯកសារនេះចុងក្រោយ ជូនដល់ក្រុមប្រឹក្សាភិបាល។

ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសមាជិក ឬភាគីនោះឡើយ។

(v) ព័ត៌មានមានម្ចាស់កម្មសិទ្ធិ ឬព័ត៌មានដែលផ្តល់ឱ្យ ADB ដោយភាគីណាមួយ ដែលប្រសិនបើបង្ហាញ នឹង ឬទំនងជាធ្វើឱ្យប៉ះពាល់ក្នុងកម្រិតមួយធ្ងន់ធ្ងរ ដល់ផលប្រយោជន៍ផ្នែកពាណិជ្ជកម្ម ផលប្រយោជន៍ហិរញ្ញវត្ថុ សមត្ថភាពប្រកួតប្រជែង របស់ភាគី ដែលជាប្រភពព័ត៌មាននោះ ឬភាគីមួយផ្សេងទៀត ដែលអាចរងផលប៉ះពាល់ ដោយសារការបង្ហាញព័ត៌មាននេះ។

(vi) ព័ត៌មានធុរកិច្ចសម្ងាត់ដែលមានចែងក្នុងកិច្ចព្រមព្រៀងរក្សាការសម្ងាត់ ឬកិច្ចព្រមព្រៀងមិនបង្ហាញព័ត៌មានដែល ADB បានព្រមព្រៀងជាមួយនឹងអតិថិជន ឬភាគីពាក់ព័ន្ធផ្សេងទៀត។

## ៣. ព័តមានផ្ទាល់ខ្លួន

(vii) ព័ត៌មានផ្ទាល់ខ្លួនទាំងឡាយណាដែល ប្រសិនបើបង្ហាញ នឹង ឬទំនងជាបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់ផលប្រយោជន៍ឯកជនស្របច្បាប់របស់សាមីជន លើកលែងតែក្នុងកម្រិតដែលអនុញ្ញាតឱ្យបាន ដោយសាមីជននោះ ឬដោយវិធាននានារបស់ ADB។ ឧទាហរណ៍ដូចជាព័ត៌មានពាក់ព័ន្ធនឹងដំណើរការតែងតាំង និងជ្រើសរើស លក្ខខណ្ឌការងារ ការវាយតម្លៃលើការអនុវត្តការងារ ព័ត៌មានសុខភាពផ្ទាល់ខ្លួន ការប្រាស្រ័យទាក់ទងផ្ទាល់ខ្លួន ព័ត៌មានពាក់ព័ន្ធនឹងនឹងនីតិវិធីដោះស្រាយទំនាស់ផ្ទៃក្នុង និងយន្តការសាទុក្ខ និងព័ត៌មានពាក់ព័ន្ធនឹងការស៊ើបអង្កេត។

## ៤. ព័ត៌មានហិរញ្ញវត្ថុ

(viii) ព័ត៌មានហិរញ្ញវត្ថុដែល ប្រសិនបើបង្ហាញ នឹង ឬទំនងជាធ្វើឱ្យមានការបង្កគ្រោះថ្នាក់លើផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់ ADB និងប្រតិបត្តិការរបស់ ADB។ ឧទាហរណ៍ ដូចជា ការប៉ាន់ប្រមាណពីកម្ចីនាពេលអនាគត ការព្យាករណ៍ហិរញ្ញវត្ថុ ទិន្នន័យអំពីការសម្រេចចិត្តវិនិយោគរបស់បុគ្គលម្នាក់ៗក្នុងប្រតិបត្តិការរតនាគាររបស់ ADB ការវាយតម្លៃឥណទាន ការវិភាគលើភាពសក្តិសមឥណទាន ចំណាត់ថ្នាក់ឥណទាន ការវាយតម្លៃហានិភ័យរបស់អ្នកខ្ចី និងអតិថិជនដទៃទៀត និងព័ត៌មានទាំងឡាយណាដែលមានលក្ខណៈរសើប ចំពោះទីផ្សារមូលធន និងទីផ្សារហិរញ្ញវត្ថុ។

(ix) ព័ត៌មានហិរញ្ញវត្ថុដែល ប្រសិនបើបង្ហាញ នឹង ឬទំនងជានាំឱ្យមានការបង្កគ្រោះថ្នាក់លើប្រទេសជាសមាជិកណាមួយក្នុងការគ្រប់គ្រងសេដ្ឋកិច្ចរបស់ខ្លួន។

## ៥. សន្តិសុខ និងសុវត្ថិភាព

(x) ព័ត៌មាន ដែលប្រសិនបង្ហាញ នឹង ឬទំនងជានឹង បង្កគ្រោះថ្នាក់ដល់ការអាយុជីវិត សុខភាព សុវត្ថិភាព ឬសន្តិសុខរបស់បុគ្គលណាម្នាក់ សុវត្ថិភាព ឬសន្តិសុខនៃនៃ

ទ្រព្យសម្បត្តិរបស់ ADB ឬធ្វើឱ្យគ្រោះថ្នាក់ដល់កិច្ចការការពារជាតិ ឬសន្តិសុខជាតិរបស់ប្រទេសជាសមាជិកណាមួយ។

## ៦. បញ្ហាច្បាប់ និងបញ្ហាពាក់ព័ន្ធនឹងការស៊ើបអង្កេត

(xi) ព័ត៌មានទាំងឡាយណា ដែលស្ថិតនៅក្នុងក្របខ័ណ្ឌបុព្វសិទ្ធិរវាងមេធាវី និងអតិថិជន (ដូចជាការប្រាស្រ័យទាក់ទងទៅកាន់ ឬមកពីមេធាវី ADB ឬទីប្រឹក្សាច្បាប់ខាងក្រៅរបស់ ADB) ឬព័ត៌មានទាំងឡាយដែល ប្រសិនបើបង្ហាញ នឹង ឬទំនងជានឹងប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់រវាងមេធាវី និងអតិថិជន ឬជាការបំពានច្បាប់ដែលកំពុងចូលជាធរមាន។[15]

(xii) ព័ត៌មានដែលផ្តល់ដល់ ADB អំពីការកេងបន្លំ អំពើពុករលួយ ឬការបំពានគោលនយោបាយប្រឆាំងនឹងអំពើពុករលួយផ្សេងទៀតរបស់ ADB[16] ឬការប្រព្រឹត្តអំពើមិនត្រឹមត្រូវ ឬព័ត៌មាន ពាក់ព័ន្ធនឹងការស៊ើបអង្កេតលើការចោទប្រកាន់ពីការកេងបន្លំ អំពើពុករលួយ ឬការបំពានគោលនយោបាយប្រឆាំងនឹងអំពើពុករលួយផ្សេងទៀតរបស់ ADB ឬការប្រព្រឹត្តអំពើមិនត្រឹមត្រូវ។ ព័ត៌មានទាំងឡាយ ដែលប្រសិនបើបង្ហាញ នឹង ឬទំនងជាបង្កផលប៉ះពាល់ពាល់គួរឱ្យកត់សម្គាល់ដល់ការស៊ើបអង្កេត ឬការស្វែងរកយុត្តិធម៌ លើកលែងតែក្នុងកម្រិតដែលអនុញ្ញាតឱ្យមានការបង្ហាញ ហើយការបង្ហាញធ្វើឡើងស្របតាមវិធានរបស់ ADB។ កថាខណ្ឌនេះ ក៏អនុវត្តចំពោះអត្តសញ្ញាណរបស់ភាគី ដែលជាអ្នកធ្វើការចោទប្រកាន់ (អ្នករាយការណ៍) ផងដែរ លើកលែងតែក្នុងករណីដែលអ្នករាយការណ៍នេះ អនុញ្ញាតឱ្យមានការបង្ហាញអត្តសញ្ញាណរបស់ខ្លួន ឬលើកលែងតែក្នុងកម្រិតដែលអនុញ្ញាតឱ្យបង្ហាញបានក្នុងវិធានរបស់ ADB ហើយការបង្ហាញនេះធ្វើឡើងដោយអនុលោមទៅតាមវិធានរបស់ ADB។

## ៧. របាយការណ៍សវនកម្មផ្ទៃក្នុង និងរបាយការណ៍សវនកម្មលើមូលនិធិ Trust Fund[17]

(xiii) (ក) របាយការណ៍សវនកម្មផ្ទៃក្នុងនៃការិយាល័យអគ្គសវនកររបស់ ADB ដោយហេតុថា របាយការណ៍ទាំងនេះ អាចមានព័ត៌មានរសើបអំពីប្រព័ន្ធផ្ទៃក្នុងដែលអាចត្រូវបានភាគីទីបី កេងចំណេញ បង្កឱ្យមានគ្រោះថ្នាក់ដល់ ADB និង (ខ) របាយការណ៍សវនកម្មមួយចំនួន របស់សវនករខាងក្រៅរបស់ ADB លើមូលនិធិ Trust Fund ដែលចាត់ចែងដោយ ADB ក្នុងករណីដែលស្តង់ដារសវនកម្មដែលត្រូវបានចូលជាធរមាន ដែលហាមឃាត់មិនឱ្យមានការបង្ហាញរបាយការណ៍ទាំងនេះ និង

15 នេះអាចរាប់បញ្ចូលការដាក់កំហិតដែលចែងក្នុងច្បាប់មូលប័ត្រ និងច្បាប់ធនាគារ និងច្បាប់ស្តីពីការរក្សាសិទ្ធិអ្នកនិពន្ធ។

16 ADB. 2010. ការប្រឆាំងអំពើពុករលួយ និងសុចរិតភាព៖ គោលនយោបាយក្របខ័ណ្ឌ និងយុទ្ធសាស្ត្ររបស់យើង។ ទីក្រុងម៉ានីល https://www.adb.org/sites/default/files/institutional-document/31317/anticorruption-integrity-policy-strategy.pdf និង ADB. 1998. គោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយ។ ទីក្រុងម៉ានីល https://www.adb.org/documents/anticorruption-policy (ដែលអាចធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់)។

17 ទស្សនៈយល់ឃើញរបស់សវនករ និងរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្ម ដែលត្រូវបានបង្ហាញជូនសាធារណជនជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់ ADB ពុំត្រូវបានគ្របដណ្តប់ដោយករណីលើកលែងនេះឡើយ។

របាយការណ៍ហិរញ្ញវត្ថុដែលពាក់ព័ន្ធនានា។[18]

## គ. ការសម្រេចចិត្តផ្ទុយពីគោលនយោបាយនេះ ដើម្បីប្រយោជន៍សាធារណៈ (ការសម្រេចចិត្តផ្ទុយជាវិជ្ជមាន)

១៨. ក្នុងកាលៈទេសៈពិសេសមួយចំនួន ADB មានសិទ្ធិបង្ហាញព័ត៌មានដែលស្ថិតក្នុងប្រភេទករណីលើកលែងមិនឱ្យបង្ហាញ ប្រសិនបើធនាគារសម្រេចឃើញថា ផលប្រយោជន៍សាធារណៈដែលបានពីការបង្ហាញពីព័ត៌មាននេះ មានលើសពីគ្រោះថ្នាក់ដែលបង្កឡើងដោយសារការបង្ហាញព័ត៌មាននេះ។ អនុសាសន៍ឱ្យបង្ហាញ ឬមិនបង្ហាញព័ត៌មាននេះ តម្រូវឱ្យមានការអនុម័តពីក្រុមប្រឹក្សាភិបាល សម្រាប់កំណត់ត្រារបស់ក្រុមប្រឹក្សាភិបាល និងពីប្រធាន ADB សម្រាប់ព័ត៌មានផ្សេងទៀត។

## ឃ. បុព្វសិទ្ធិរបស់ ADB ក្នុងការកំហិតលើការទទួលបានព័ត៌មាន (ការសម្រេចចិត្តផ្ទុយជាអវិជ្ជមាន)

១៩. ក្នុងកាលៈទេសៈពិសេសមួយចំនួន ADB ក៏មានសិទ្ធិមិនបង្ហាញព័ត៌មានដែលខ្លួនធ្លាប់តែបង្ហាញជាធម្មតា ប្រសិនបើធនាគារសម្រេចឃើញថា ការបង្ហាញព័ត៌មានទាំងនេះនឹង ឬទំនងជាបង្កឱ្យមានគ្រោះថ្នាក់លើសពី អត្ថប្រយោជន៍ដែលទទួលបានពីការបង្ហាញព័ត៌មាននេះ។ មានតែក្រុមប្រឹក្សាភិបាលតែប៉ុណ្ណោះ ដែលអាចមានបុព្វសិទ្ធិនេះ។

## ង. ព័ត៌មានប្រវត្តិសាស្ត្រ

២០. ព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ ADB ដែល ADB រក្សាទុកជាង ២០ ឆ្នាំ ចាប់គិតពីកាលបរិច្ឆេទដែលព័ត៌មាននេះត្រូវបានផលិតដោយ ADB ឬផ្តល់ឱ្យ ADB ត្រូវបានចាត់ទុកថាជាព័ត៌មានប្រវត្តិសាស្ត្រ។ ឯកសារប្រវត្តិសាស្ត្ររបស់ក្រុមប្រឹក្សាភិបាល គឺជាឯកសារដែលអាចបង្ហាញបាន បន្ទាប់ពីមានការស្នើសុំ ដរាបណាគណៈកម្មាធិការទទួលបានសិទ្ធិទទួលបានព័ត៌មាន (AIC) សម្រេចឃើញថា ឯកសាររបស់ក្រុមប្រឹក្សាភិបាលទាំងនេះ ពុំមាន ឬពុំលើកឡើងពីព័ត៌មានដែលឋិតក្នុងប្រភេទករណីលើកលែងក្នុងគោលនយោបាយនេះ ដោយធ្វើការពិចារណាពីប្បញ្ញត្តិក្នុងកថាខណ្ឌ ៥.១ (ii)។ រាល់ព័ត៌មានប្រវត្តិសាស្ត្រទាំងអស់ផ្សេងទៀត ជាព័ត៌មានដែលអាចបង្ហាញបាន បន្ទាប់ពីមានការស្នើសុំ លើកលែងតែព័ត៌មានដែលស្ថិតក្នុងប្រភេទករណីលើកលែងដែលរៀបរាប់ក្នុងកថាខណ្ឌ ៥.២ (ព័ត៌មានដែលផ្តល់ដោយសម្ងាត់) ៥.៣ (ព័ត៌មានផ្ទាល់ខ្លួន) ៥.៥ (ព័ត៌មានពាក់ព័ន្ធនឹង សន្តិសុខ និងសុវត្ថិភាព) ឬ ៥.៦ (បញ្ហាច្បាប់ ឬបញ្ហាពាក់ព័ន្ធនឹងការស៊ើបអង្កេត) ដែលត្រូវបន្តឋិតក្នុងករណីលើកលែងមិនឱ្យមានការបង្ហាញ។

18 របាយការណ៍ហិរញ្ញវត្ថុមួយចំនួនរបស់មូលនិធិ Trust Fund ត្រូវបានរាប់ចំឡើងស្របតាមលក្ខខណ្ឌគណនេយ្យរបស់អ្នកផ្តល់ជំនួយ (ដែលអាចមានលក្ខណៈខុសប្លែកពីស្តង់ដារគណនេយ្យ ដែលត្រូវបានទទួលយកជាទូទៅនៅសហរដ្ឋអាមេរិក) ហើយត្រូវបានធ្វើសវនកម្មស្របតាមស្តង់ដារគណនេយ្យដែលត្រូវបានទទួលយកជាទូទៅក្នុងសហរដ្ឋអាមេរិក (ដោយអនុវត្តចំពោះ ADB)។ ស្តង់ដារសវនកម្មទាំងនេះ ដាក់កំហិតលើការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានរៀបចំឡើងស្របតាមស្តង់ដារគណនេយ្យ ក្រៅតែពីស្តង់ដារដែលត្រូវបានទទួលយកជាទូទៅនៅសហរដ្ឋអាមេរិក និងគំនិតរបស់សវនករ ពាក់ព័ន្ធចពោះអ្នកដែលមានផលប្រយោជន៍ក្នុងមូលនិធិនេះ ឧទាហរណ៍ អ្នកផ្តល់ភាគទាន និងអ្នកដែលទទួលខុសត្រូវលើការគ្រប់គ្រង និង/ឬ ចាត់ចែងមូលនិធិនេះជាដើម។

# IV. សំណើសុំព័ត៌មាន និងបណ្តឹងសាទុក្ខ

## ក. សំណើសុំព័ត៌មាន

២១. រាល់សំណើសុំព័ត៌មាន និងឯកសារទាំងអស់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ គេអាចដាក់សំណើនេះ ទៅកាន់ការិយាល័យកណ្តាលរបស់ ADB និវាសនដ្ឋាន ការិយាល័យតំណាង ឬនាយកដ្ឋាន ឬការិយាល័យណាមួយរបស់ ADB។ ព័ត៌មានលម្អិតអំពីកន្លែងផ្ញើសំណើសុំព័ត៌មាន មានបង្ហាញលើវិបសាយរបស់ ADB។ សំណើទាំងនេះ គួរធ្វើការបញ្ជាក់ឱ្យបានសមស្របនូវព័ត៌មានដែលអ្នកស្នើចង់បាន ដើម្បីឱ្យ ADB អាចស្វែងរកព័ត៌មាននោះ ក្នុងរយៈពេលមួយសមស្រប។

២២. សំណើនេះអាចដាក់ជូន ADB ជាភាសាអង់គ្លេស ឬភាសាផ្លូវការ ឬភាសាជាតិណាមួយនៃប្រទេសជាសមាជិករបស់ ADB។[19]

២៣. ADB មិនមានកាតព្វកិច្ចគោរពតាម ឬឆ្លើយតបចំពោះសំណើដែលពុំមានឯកសារគាំទ្រសំណើសុំព័ត៌មានទូទៅ ឬសំណើដែលតម្រូវឱ្យ ADB បង្កើត រៀបចំ ឬប្រមូលព័ត៌មាន ឬទិន្នន័យដែលពុំមានស្រាប់ ឬពុំអាចរកបានក្នុងប្រព័ន្ធគ្រប់គ្រងឯកសាររបស់ ADB ឡើយ។ ចំណុចនេះ ក៏អនុវត្តចំពោះសំណើព័ត៌មានអំពីកម្មវត្ថុដដែលពីបុគ្គល ស្ថាប័ន ឬក្រុម ដែល ADB ធ្លាប់បានផ្តល់ព័ត៌មានបែបនេះម្តងរួចហើយ បន្ទាប់ពីបានទទួលសំណើកាលពីលើកមុន ឬបានបញ្ជាក់ពីមូលហេតុថា ADB ពុំអាចផ្តល់ព័ត៌មាននេះរួចហើយ។

២៤. ADB ត្រូវបញ្ជាក់ភ្លាមៗថា បានទទួលសំណើ និងត្រូវបង្ហាញពីការសម្រេចចិត្តរបស់ខ្លួន ទាក់ទិននឹងសំណើនេះ។[20] សម្រាប់សំណើដែលមានលក្ខណៈស្មុគស្មាញ[21] ADB អាចពន្យារកាលបរិច្ឆេទឆ្លើយតបចំពោះសំណើនេះ ដរាបណាមានការជូនដំណឹងដល់អ្នកស្នើសុំ ហើយអ្នកស្នើសុំបានទទួលយកការពន្យារកាលបរិច្ឆេទកំណត់នេះ។

## ខ. គណៈកម្មាធិការទទួលបន្ទុកសិទ្ធិទទួលបានព័ត៌មាន

២៥. គណៈកម្មាធិការទទួលបន្ទុកសិទ្ធិទទួលបានព័ត៌មាន (AIC) គឺជាស្ថាប័នត្រួតពិនិត្យដែលត្រូវបានបង្កើតឡើង ដើម្បីបំពេញតួនាទីបកស្រាយ ពិនិត្យតាមដាន និងពិនិត្យ

19 ភាសាអង់គ្លេស ត្រូវបានប្រើប្រាស់ជាភាសាស្តង់ដារសម្រាប់ការឆ្លើយតបរបស់ ADB ចំពោះសំណើនានា។ ការឆ្លើយតបអាចបកប្រែជូនអាស្រ័យទៅតាមកាលៈទេសៈជាក់ស្តែង។

20 ក្នុងករណីដែល ADB ប្រើប្រាស់បុព្វសិទ្ធិរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌទី ៥ (ការសម្រេចចិត្តផ្ទុយជាវិជ្ជមាន) ឬកថាខណ្ឌទី ៧ (ការសម្រេចចិត្តផ្ទុយអវិជ្ជមាន) ADB ត្រូវប្រាប់ទៅកាន់អ្នកស្នើសុំបន្ទាប់ពីមានការសម្រេចចិត្តចុងក្រោយ។ អ្នកស្នើសុំនឹងទទួលបានការជូនដំណឹងអំពីការពន្យារកាលបរិច្ឆេទកំណត់ ទៅតាមការសមស្រប។

21 សំណើសុំព័ត៌មានដែលមានលក្ខណៈស្មុគស្មាញ មានដូចជាការស្វែងរកព័ត៌មានពីប្រភពចម្រុះ ពីឯកសារក្នុងចំនួនដ៏ច្រើន ការប្រមូលព័ត៌មានពីច្រើនឆ្នាំ ការប្រមូល និងការភ្ជាប់ទំនាក់ទំនងរវាងទិន្នន័យមិនទាន់វិភាគ (raw data) និងការបង្ហាញពីលទ្ធផលរកឃើញផ្សេងៗ។

ឡើងវិញ លើគោលនយោបាយនេះ និងការរៀបចំការអនុវត្តគោលនយោបាយនេះ។ គណៈកម្មាធិការនេះ មានសមាសភាពជាបុគ្គលិកជាន់ខ្ពស់របស់ ADB ដែលត្រូវបានតែងតាំងដោយប្រធានធនាគារ និងត្រូវរាយការណ៍ទៅកាន់ប្រធានធនាគារ។ AIC ត្រូវកោះប្រជុំទៅតាមការចាំបាច់ ដើម្បីពិនិត្យលើសំណើសុំព័ត៌មាន ដែលត្រូវបានបដិសេធដោយនាយកដ្ឋាន ឬការិយាល័យរបស់ ADB។ AIC ក៏ត្រូវធ្វើការពិចារណា និងធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខ (កថាខណ្ឌទី ១៦) ផងដែរ។ AIC មានសមត្ថកិច្ច (i) តម្កល់ការសម្រេច ឬសម្រេចផ្ទុយនឹងការសម្រេចរបស់នាយកដ្ឋាន និងការិយាល័យរបស់ ADB ដែលបដិសេធមិនផ្តល់ព័ត៌មាន និង (ii) ពិចារណាលើសំណើសុំឱ្យមានការបង្ហាញព័ត៌មានដែលស្ថិតនៅក្នុងប្រភេទករណីលើកលែងក្នុងគោលនយោបាយនេះ ដើម្បីប្រយោជន៍សធារណៈ (កថាខណ្ឌទី ៦)។

## គ. បណ្តឹងសាទុក្ខ

២៦. ADB មានដំណើរការបណ្តឹងសាទុក្ខ ចែកជាពីរដំណាក់កាល ដែលអ្នកស្នើសុំព័ត៌មានអាចប្រើប្រាស់នៅពេលដែលពួកគេជឿថា ការបដិសេធរបស់ ADB លើសំណើសុំព័ត៌មានរបស់ពួកគេ ជាការបំពានគោលនយោបាយនេះ។ ព័ត៌មានលម្អិតអំពីកន្លែងដាក់បណ្តឹងសាទុក្ខ មានបង្ហាញក្នុងវិបសាយរបស់ ADB។ ដំណោះស្រាយដែលមានសម្រាប់អ្នកស្នើសុំក្នុងដំណើរការបណ្តឹងសាទុក្ខណាមួយ ត្រូវបានកំហិតត្រឹមតែជាការទទួលបានព័ត៌មានដែលស្នើសុំនោះតែប៉ុណ្ណោះ។

២៧. ដំណើរការបណ្តឹងសាទុក្ខ បែងចែកជាពីដំណាក់កាល ដូចខាងក្រោម៖

### ១. ដំណាក់កាលទីមួយ៖ គណៈកម្មាធិការទទួលបន្ទុកសិទ្ធិទទួលបានព័ត៌មាន

២៨. អ្នកស្នើសុំដែល ADB បដិសេធមិនផ្តល់ព័ត៌មានឱ្យ អាចដាក់បណ្តឹងសាទុក្ខទៅកាន់ AIC ប្រសិនបើអ្នកស្នើសុំនេះ អាច (i) បង្ហាញថា សំណើសុំព័ត៌មានដំបូងត្រូវបានដាក់ស្របតាមនីតិវិធី ដែលមានចែងក្នុងគោលនយោបាយនេះ និង (ii) ផ្តល់នូវទឡ្ហីករណ៍សមស្របបញ្ជាក់ថា ADB បានបំពានគោលនយោបាយនេះ តាមរយៈការបដិសេធមិនផ្តល់ព័ត៌មានដែលស្នើសុំ ឬលើកឡើងពីទឡ្ហីករណ៍ ដើម្បីប្រយោជន៍សាធារណៈ ដូចរៀបរាប់ក្នុងកថាខណ្ឌទី ៦ ដើម្បីឱ្យមានការសម្រេចចិត្តផ្ទុយពីករណីលើកលែងក្នុងគោលនយោបាយនេះ។

### ២. ដំណាក់កាលទីពីរ៖ គណៈកម្មាធិការឯករាជ្យទទួលបន្ទុកពិនិត្យលើបណ្តឹងសាទុក្ខ

២៩. ប្រសិនបើ AIC តម្កល់ការសម្រេចចិត្តដំបូង ដែលបដិសេធមិនផ្តល់ព័ត៌មានតាមសំណើ ហើយអ្នកស្នើសុំ នៅតែជឿថា ADB បានបំពានគោលនយោបាយរបស់ខ្លួនតាមរយៈការមិនផ្តល់ព័ត៌មាននេះ អ្នកស្នើសុំអាចដាក់ បណ្តឹងសាទុក្ខទៅកាន់គណៈកម្មាធិការឯករាជ្យទទួលបន្ទុកពិនិត្យលើបណ្តឹងសាទុក្ខ (IAP)។ IAP មានសមត្ថកិច្ចតម្កល់ ឬធ្វើ

ការសម្រេចចិត្តផ្ទុយនឹងការសម្រេចចិត្តរបស់ AIC។ ការសម្រេចរបស់ IAP គឺជាការសម្រេចចិត្តស្ថាពរ។

៣០. IAP ពុំមានអំណាចធ្វើការពិចារណាលើបំណងសាទុក្ខ ពាក់ព័ន្ធនឹង (i) ការសម្រេចចិត្តដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល ឬប្រធានធនាគារ ប្រសិនបើបណ្តឹងសាទុក្ខនេះ ធ្វើឡើងទៅតាមការស្នើសុំឱ្យមានការសម្រេចចិត្តផ្ទុយពីគោលនយោបាយនេះ ដើម្បីប្រយោជន៍សាធារណៈ ឬ (ii) ការសម្រេចរបស់ក្រុមប្រឹក្សាភិបាលក្នុងការប្រើប្រាស់បុព្វសិទ្ធិរបស់ខ្លួន ដើម្បីដាក់កំហិតលើសិទ្ធិទទួលបានព័ត៌មាន ដែលធ្លាប់តែងបង្ហាញជាធម្មតា។

៣១. IAP មានសមាសភាពជាអ្នកជំនាញខាងក្រៅបីរូប ដែលមានឯកទេសខាងសិទ្ធិទទួលបានព័ត៌មាន និងបំពេញតួនាទីឯករាជ្យពី ADB។ ប្រធាន ADB តែងតាំងសមាជិក IAP ដោយមានការអនុម័តពីក្រុមប្រឹក្សាភិបាល។

### ៣. ការដាក់បណ្តឹងសាទុក្ខ និងការជូនដំណឹងពីសេចក្តីសម្រេច

៣២. បណ្តឹងសាទុក្ខទាំងអស់ដែលដាក់ទៅកាន់ AIC ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្នុងអំឡុង ៩០ ថ្ងៃប្រតិទិន បន្ទាប់ពីសេចក្តីសម្រេចដំបូងរបស់ ADB ដែលបដិសេធមិនផ្តល់ព័ត៌មានតាមការស្នើសុំ។ រាល់បណ្តឹងសាទុក្ខ ដែលដាក់ជូន IAP ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីការសម្រេចរបស់ AIC ក្នុងការតម្កល់ការសម្រេចដំបូងរបស់ ADB ដែលបដិសេធមិនឱ្យមានការផ្តល់ព័ត៌មាន។ បណ្តឹងសាទុក្ខដែលទទួលក្រោយរយៈពេល ៩០ ថ្ងៃ ដែលជារយៈពេលសម្រាប់ដាក់បណ្តឹងសាទុក្ខ ពុំត្រូវលើកយកមកធ្វើការពិចារណានោះឡើយ។ រាល់បណ្តឹងសាទុក្ខទាំងអស់ ត្រូវមានព័ត៌មានដូចខាងក្រោម៖

(i) សេចក្តីពិពណ៌នាអំពីព័ត៌មានដែលស្នើសុំពីដំបូង និង

(ii) សេចក្តីពន្យល់ដែលបង្ហាញពីអង្គហេតុ និងមូលហេតុដែលគាំទ្រអំណះអំណាងរបស់អ្នកស្នើសុំ ដែលថា ADB បានបំពានគោលនយោបាយនេះ ហើយដែលបញ្ជាក់ថា ត្រូវមានការសម្រេចផ្ទុយពីប្បញ្ញត្តិក្នុងគោលនយោបាយនេះ ដើម្បីប្រយោជន៍សាធារណៈ។

៣៣. អ្នកស្នើសុំ នឹងទទួលបានការជូនដំណឹង ប្រសិនបើបណ្តឹងសាទុក្ខត្រូវបានទាត់ចោល (i) ដោយសារការពុំបានដាក់បណ្តឹងសាទុក្ខនៅក្នុងរយៈពេលដែលបានកំណត់ (ii) ដោយសារការខកខានពុំបានផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់សម្រាប់គាំទ្រដល់បណ្តឹងសាទុក្ខនេះ ឬ (iii) ដោយសារតែ AIC ឬ AIP ពុំមានអំណាចធ្វើការពិចារណាលើកម្មវត្ថុនៃបណ្តឹងសាទុក្ខនេះ។

## ឃ. ទំនាក់ទំនងរវាងគោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាន ជាមួយនឹងគោលនយោបាយផ្សេងទៀត

៣៤. ការលើកឡើងពីគោលនយោបាយផ្សេងទៀតរបស់ ADB ក្នុងគោលនយោបាយនេះ គឺសំដៅលើគោលនយោបាយនានា រួមទាំងគោលនយោបាយដែលមានការកែសម្រួលជាបន្តបន្ទាប់ផងដែរ។

## ង. ការពិនិត្យឡើងវិញលើភាពអនុលោម

៣៥. គោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាននេះ ជាកម្មវត្ថុនៃដំណើរការបណ្តឹងសាទុក្ខ (កថាខណ្ឌទី ១៤-២១)។ គោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាន គឺជា "គោលនយោបាយប្រតិបត្តិការ" ដែលស្ថិតក្រោមក្របខ័ណ្ឌនៃគោលនយោបាយស្តីពីយន្តការគណនេយ្យភាពរបស់ ADB។ ដូច្នេះ បណ្តឹងទាំងឡាយដែលប្តឹងដោយជនរងផលប៉ះពាល់ដោយសារគម្រោង ដែលចោទប្រកាន់ថា ADB បានបំពានគោលនយោបាយនេះ ក្នុងអំឡុងពេលរៀបចំដំណើរការ ឬអនុវត្តគម្រោងណាមួយ ក៏អាចដាក់ពាក្យបណ្តឹងក្រោមក្របខ័ណ្ឌនៃគោលនយោបាយស្តីពីយន្តការគណនេយ្យភាពរបស់ ADB ផងដែរ។[22]

22 យន្តការគណនេយ្យភាព គឺជាវេទិកាសម្រាប់ឱ្យអ្នកដែលរងផលប៉ះពាល់ជាអវិជ្ជមាន ដោយសារគម្រោងដែលគាំទ្រដោយ ADB អាចបញ្ចេញសម្លេង និងស្វែងរកដំណោះស្រាយចំពោះបញ្ហានានា និងរាយការណ៍ពីភាពមិនអនុលោមទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការរបស់ ADB។ យន្តការគណនេយ្យភាព https://www.adb.org/site/accountability-mechanism/main

# V. ការពិនិត្យតាមដាន និងការកែសម្រួលគោលនយោបាយនេះ

៣៦. ADB នឹងពិនិត្យតាមដានការអនុវត្តគោលនយោបាយនេះ នឹងផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំលើវិបសាយរបស់ខ្លួន។ ការកែសម្រួលគោលនយោបាយនេះ អាចធ្វើឡើងជាបន្តបន្ទាប់ បន្ទាប់ពីមានការឯកភាពពីក្រុមប្រឹក្សាភិបាល។

# VI. កាលបរិច្ឆេទចូលជាធរមាន នៃគោលនយោបាយនេះ

៣៧. គោលនយោបាយនេះ ចូលជាធរមាននៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៩ និងមានឧត្តមភាពលើគោលនយោបាយស្តីពីទំនាក់ទំនងសាធារណៈឆ្នាំ ២០១១។

## អំពីធនាគារអភិវឌ្ឍន៍អាស៊ី

ធនាគារអភិវឌ្ឍន៍អាស៊ីបានប្តេជ្ញាចិត្តក្នុងការសំរេចបាននូវតំបន់អាស៊ីនិងប៉ាស៊ីហ្វិកប្រកបដោយភាពរឹងមាំមានគ្រប់ជ្រុងជ្រោយរឹងមាំនិងមាននិរន្តភាពខណៈដែលកំពុងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីលុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ។ បង្កើតឡើងក្នុងឆ្នាំ ១៩៦៦ វាត្រូវបានគ្រប់គ្រងដោយសមាជិកចំនួន ៦៧ នាក់មកពី ៤៨ ប្រទេស។ ឧបករណ៍សំខាន់ៗរបស់ខ្លួនក្នុងការជួយប្រទេសកំពុងអភិវឌ្ឍន៍របស់ខ្លួនគឺកិច្ចសន្ទនាគោលនយោបាយប្រាក់កម្ចីការវិនិយោគមូលធន ការធានាជំនួយ និងជំនួយបច្ចេកទេស។

ADB

**ធនាគារអភិវឌ្ឍន៍អាស៊ី**

អគារលេខ ៦ វិថី ADB Avenu ក្រុង Mandaluyong
ទីក្រុងម៉ានីល ១៥៥០ ប្រទេសហ្វីលីពីន
www.adb.org